# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

## របាយការណ៍កិច្ចប្រជុំ
## ក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

១. **ថ្ងៃ ខែ ឆ្នាំ៖** ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣

២. **ទីកន្លែង៖** នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមប្រព័ន្ធអនឡាញ(Zoom)

៣. ប្រធាន និងសមាសភាពចូលរួម ៖

១- ប្រធានអង្គប្រជុំ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២- សមាសភាពចូលរួមមាន សមាជិក សមាជិកាថ្នាក់បច្ចេកទេសអន្តរក្រសួង ស្ថាប័ន រាជធានី ខេត្ត និងអង្គការពាក់ព័ន្ធ ដែលចូលរួមផ្ទាល់ចំនួន៣០រូប និងតាមប្រព័ន្ធអនឡាយចំនួន២៥រូប សរុបចំនួន៥៥រូប។

៤. របៀបវារៈ៖

១-មតិស្វាគមន៍ និងគោលបំណងនៃកិច្ចប្រជុំដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស។

២-បទបង្ហាញស្តីពីការពិភាក្សាស្វែងយល់ពី "ការប៉ាន់ប្រមាណ ចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ក្រោមជាតិ" ដោយ **លោកវេជ្ជ កាអឿន ចិត្រា** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

៣-មតិបូកសរុប និងបិទកម្មវិធីដោយ **ឯកឧត្តមបណ្ឌិត ឈឹម ឃិនជារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជំងឺអេដស៍។

៥. លទ្ធផល ៖

ជាកិច្ចចាប់ផ្ដើម **ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមប្រឹក្សាបច្ចេកទេស បានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

ដំណើរការនៃកិច្ចប្រជុំមាន៖

**ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសមាជិក សមាជិកានៃកិច្ចប្រជុំ និងបានបញ្ជាក់ថាការគិតគូអំពីទិន្នន័យទាក់ទងនឹងកម្មវិធីឆ្លើយតបមេរោគអេដស៍ ជំងឺអេដស៍នៅតែជាចំណុចជាអាទិភាព ដើម្បីទទួលបាននូវបទអន្តរាគមន៍បង្ការ ដែលមានលក្ខណៈសុក្រឹតជាក់លាក់ក្នុងការយកមកប្រើប្រាស់ ដើម្បីសម្រេចបាននូវការសម្រេចចិត្តបានត្រឹមត្រូវ និងទាន់ពេលវេលា ដែលផ្ដោតទៅលើគោលនយោបាយលុបបំបាត់ការឆ្លងរីករាលដាលនៃមេរោគអេស៍ និងជំងឺអេដស៍ និងចីរភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

តាមរយៈនៃកិច្ចប្រជុំ លោកវេជ្ជបណ្ឌិត **កាអៀន ចិត្រា** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ បានធ្វើបទបង្ហាញអំពី ការប៉ាន់ប្រមាណ ចំនួនអ្នកផ្ទុកមេរោគអេដស៍ថ្នាក់ក្រោមជាតិ ។

-តាមការប៉ាន់ស្មាន ទិន្នន័យបានមក ពីករណីផ្ទុកមេរោគអេដស៍ អ្នកប្រឈមមុខខ្ពស់ អ្នកឆ្លងថ្មី ជំហ៊ានដែលត្រូវធ្វើបន្ត។

-ស្វែងយល់ពីនិន្នាការអ្នកផ្ទុកមេរោគអេដស៍ ករណីឆ្លងថ្មី ករណីស្លាប់ នៅតាមខេត្ត និងក្រុមប្រឈមមុខខ្ពស់។

-វឌ្ឍនភាពនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ស្របតាមគោលដៅ ៩៥ ៩៥ ៩៥។

-ផ្ដល់ព័ត៌មានដល់ថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការ និងកំណត់អាទិភាពឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

-ពីការសិក្សា និងវិភាគដោយប្រមូលព័ត៌មាន គិតចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២២ លទ្ធផលដែលបានរកឃើញបានបែងចែកទៅតាម អាយុ ភេទ ទីកន្លែង និងអត្រាប្រើប្រាស់ថ្នាំជាដើម ។

-ចំនួនអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងក្រុមប្រឈមគឺមាន ៦ខេត្ត ក្នុងចំណោម ២៥ខេត្ត ដែល គ្របដណ្ដប់ជាង ៦០ភាគរយ នៃចំនួនសរុបទាំងអស់ទូទាំងប្រទេស។ ដោយឡែក ស្ត្រីបម្រើសេវាកម្សាន្ត មានការធ្លាក់ចុះ គិតចាប់ពី ឆ្នាំ២០១០ នៅពេលដែលក្រុមប្រឈមមុខខ្ពស់ ( KP ) មានការកើនឡើងគួរឱ្យព្រួយបារម្ភ ។

ក្នុងកំរិតបច្ចេកទេសបានរកឃើញថា ចំនួនអ្នកឆ្លងថ្មីច្រើនជាងគេមានពីរខេត្តគឺ ខេត្តតាកែវ និង ខេត្តព្រះសីហនុ ជាពិសេសក្រុមប្រឈមមុខខ្ពស់ ហើយទិន្នន័យនេះមិនទាន់បានបញ្ចូលទិន្នន័យ PreP នៅក្នុងកម្មវិធីនៅឡើយ ហើយដែលនឹងមានគម្រោងពង្រីកការគ្របដណ្តប់ឱ្យបានលើសពី១ម៉ឺននាក់។

ចំពោះទិន្នន័យដែលបានយកមកបង្ហាញជូនដល់សមាជិកក្រុមប្រឹក្សាបច្ចេកទេសនេះ មិនទាន់បានដាក់ផ្សព្វផ្សាយជាផ្លូវការនៅឡើយទេ យើងនៅកែសម្រួលខ្លះៗទៀត ទើបអាចផ្សព្វផ្សាយជាផ្លូវការបាន។

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិតអគ្គលេខាធិការ បានផ្តល់អនុសាសន៍ដល់សមាជិក សមាជិកាបន្តសហការ និងសម្របសម្រួលការមួយអាជ្ញាធរពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិលជំរុញការងារផ្សព្វផ្សាយដល់ប្រជាជនគោលដៅឱ្យបន្តការអប់រំ ផ្សព្វផ្សាយការយល់ដឹងអំពីមេរោគអេដស៍ និងជំងឺអេដស៍គ្រប់មធ្យោបាយ ដល់ប្រជាជនប្រឈមមុខខ្ពស់ ជាពិសេសក្រុមយុវវ័យ ដើម្បីបង្ការខ្លួនចៀសពីការឆ្លងមេរោគអេដស៍ និងលុបបំបាត់ការរើសអើង និងមាក់ងាយក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ និងប្រជាជនគន្លឹះ។

**ឯកឧត្តមបណ្ឌិត ឈឹម ឃិនដារ៉េត** បានធ្វើការបញ្ជាក់ថា ការប៉ាន់ស្មានមេរោគអេដស៍ថ្មី បានបង្ហាញថា ការកើនឡើងសមាមាត្រនៃការឆ្លង មេរោគអេដស៍ថ្មីគឺស្ថិតក្នុងចំណោមបុរស និងក្មេងប្រុស ពួកគេមានចំនួន៧៩% នៃការឆ្លងមេរោគអេដស៍ថ្មីទាំងអស់ក្នុងឆ្នាំ២០២២។ តាមចំនួនប្រជាជន៨៣% នៃការឆ្លងមេរោគអេដស៍ថ្មី សរុបគឺស្ថិតក្នុងចំណោម ប្រជាជនគន្លឹះ បុរសរួមភេទជាមួយបុរស ស្ត្រីបំប្លែងភេទ អ្នកដែលប្រើប្រាស់និងចាក់ថ្នាំញៀន និងដៃគូផ្លូវភេទរបស់ពួកគេ។ សមិទ្ធិផលរបស់ប្រទេសកម្ពុជា ត្រូវបានចាត់ទុកជាគំរូ ក្នុងការសម្រេចបានខ្ពស់បំផុតនូវអត្រាទទួលសេវាព្យាបាល និងអត្រាកាត់បន្ថយមេរោគមកកម្រិតទាបបំផុតក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

នាឱកាសនោះ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការប្រធានអង្គប្រជុំបានបញ្ជាក់ថា នឹងទទួលយកសំណើនៅក្នុងកិច្ចប្រជុំដែលបានលើកឡើងនឹងពិភាក្សាជាមួយក្រុមការងារ ដោយយើងមិនអាចធ្វើបានគ្រប់គ្នាទេ យើងត្រូវជ្រើសរើសថាតើគួរធ្វើទៅលើក្រុមណាដែលងាយប្រឈម។ ឯកឧត្តម ក៏បានបន្តថា ជាក់ស្តែងប្រទេសកម្ពុជាយើង នៅមានឧបសគ្គក្នុងការសម្រេចឱ្យបាននូវគោលដៅ៩៥ ទី១ដែលនៅឆ្ងាយពីគោលដៅកំណត់ និងដែលទាមទារឱ្យយើងទាំងអស់គ្នាត្រូវបន្តរួមគ្នា រកវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពផ្សេងៗទៀត ដើម្បីសម្រេចគោលដៅនេះ។

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិត** អគ្គលេខាធិការ ប្រធានអង្គប្រជុំក៏បានបន្ថែមថា ការងារប្រយុទ្ធនឹងមេរោគអេដស៍ នៅមានរយៈពេលយូរទៅមុខទៀត ដែលតម្រូវឱ្យយើងបន្តធ្វើការរួមគ្នា រវាងអ្នកធ្វើគោលនយោបាយ និងយុទ្ធសាស្ត្រ អ្នកផ្តល់សេវា និងអ្នករងផលប៉ះពាល់។ ម្យ៉ាងទៀតត្រូវពង្រឹងភាពជាម្ចាស់ ចាំបាច់ត្រូវមានការផ្លាស់ប្តូរ ដើម្បីពិនិត្យលទ្ធភាពបង្កើនការផ្តល់ថវិកាជាតិ ដោយឡែកដល់ថ្នាក់ក្រោមជាតិ ដែលរួមមានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រុង ស្រុក ខណ្ឌ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ឃុំ សង្កាត់ ដើម្បីបង្កើនបទអន្តរាគមន៍ឆ្លើយតបមេរោគអេដស៍ និង

ជំងឺអេដស៍ឱ្យចំលើការងារជាអាទិភាព ពិសេសក្រុមប្រឈមមុខខ្ពស់ និងទីតាំងអាទិភាពដែលមានការចម្លងច្រើនដោយប្រើអន្តរាគមន៍ដែលមានប្រសិទ្ធភាពខ្ពស់ និងជាបណ្តើរៗជានាចីរភាព និងមានភាពធន់នៃប្រព័ន្ធជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍។

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣

បានពិនិត្យត្រឹមត្រូវ

អ្នកធ្វើរបាយការណ៍

ជ.ប្រធាននាយកដ្ឋានទាក់ទង និងចលនាប្រភពធនធាន

ប្រធានអង្គប្រជុំ

សាយ ប៊ុណ្ណា

ស៊ឹ ឆា

**បណ្ឌិត ឈឹម យិនដារ៉េត**